សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំង

# ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A

## អ្វីដែលអ្នកត្រូវដឹង

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំងជាច្រើនមានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ សូមចូលទៅ www.immunize.org/vis

## 1 តើជំងឺរលាកថ្លើមប្រភេទ A គឺជាជំងឺអ្វី?

ជំងឺរលាកថ្លើប្រភេទ A គឺជាជំងឺថ្លើមធ្ងន់ធ្ងរដែលបង្កឡើងមេរោគជំងឺរលាកថ្លើមប្រភេទ A (HAV)។ មេរោគ HAV មានក្នុងលាមករបស់អ្នកមានជំងឺរលាកថ្លើមប្រភេទ A។

ជាធម្មតា ជំងឺនេះឆ្លងតាមរយៈការប៉ះពាល់ផ្ទាល់ និងពេលខ្លះ តាមរយៈការម្ហូបអាហារ ឬផឹកទឹកដែលមានមេរោគ HAV។ អ្នកដែលមានជំងឺរលាកថ្លើមប្រភេទ A អាចចម្លងជំងឺនេះទៅឲ្យអ្នកដទៃក្នុងគ្រួសារតែមួយបានយ៉ាងងាយ។

ជំងឺរលាកថ្លើមប្រភេទ A អាចបង្ក៖

- ជំងឺ"ដូចគ្រុនផ្តាសាយ"
- ជំងឺខាន់លឿង (ស្បែក ឬភ្នែកព៌ណលឿង ទឹកនោមព៌ណខ្មៅ)
- ឈឺពោះធ្ងន់ធ្ងរ និងរោគរាគរូស (កុមារ)

ជារឿយៗ អ្នកមានជំងឺរលាកថ្លើមប្រភេទ A ត្រូវដេកសម្រាកព្យាបាលនៅមន្ទីរពេទ្យ (មនុស្សប្រហែលម្នាក់ក្នុងចំណោម 5 នាក់)។

ជារឿយៗ មនុស្សពេញវ័យ ដែលមានជំងឺរលាកថ្លើមប្រភេទ A ឈឺខ្លាំងពេកមិនអាចទៅធ្វើការបានរយៈពេលដល់ទៅមួយខែ។

ពេលខ្លះ មនុស្សស្លាប់បាត់បង់ជីវិតដោយសារជំងឺរលាកថ្លើមប្រភេទ A (ស្លាប់ប្រហែល 3–6 នាក់ក្នុង 1,000 ករណី)។

ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A អាចបង្ការជំងឺរលាកថ្លើមប្រភេទ A បាន។

## 2 តើអ្នកណាគួរទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A ហើយនៅពេលណា?

### តើអ្នកណា?

*មនុស្សមួយចំនួនគួរចាក់ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A។*

- កុមារទាំងអស់អាយុពីមួយឆ្នាំដល់ពីរឆ្នាំ (12 ទៅ 23 ខែ)
- អ្នកមានអាយុ 1 ឆ្នាំ និងលើសនេះដែលធ្វើដំណើរទៅ ឬធ្វើការក្នុងប្រទេសនានាដែលមានអត្រាប្រេវ៉ាឡង់ជំងឺរលាកថ្លើមប្រភេទ A ខ្ពស់ ឬមធ្យម ដូចជា បណ្តាលប្រទេសនៅអាមេរិកកណ្តាល ឬខាងត្បូង ប្រទេសម៉ិចស៊ិក អាស៊ី (លើកលែងតែជប៉ុន) អាហ្វ្រិក និងអឺរ៉ុបខាងកើត។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ **www.cdc.gov/travel**។
- កុមារ និងយុវជនអាយុពី 2 ដល់ 18 ឆ្នាំ ដែលរស់នៅក្នុងរដ្ឋ ឬសហគមន៍ ដែលធ្វើការចាក់ថ្នាំវ៉ាក់សាំងនេះជាទម្លាប់ ដោយសារតែមានករណីជំងឺនេះច្រើន។
- បុរសដែលរួមភេទជាមួយនឹងបុរសដូចគ្នា។
- អ្នកដែលប្រើប្រាស់ថ្នាំញៀនតាមផ្លូវ។
- អ្នកមានជំងឺថ្លើមរ៉ាំរ៉ៃ
- អ្នកដែលព្យាបាលដោយថ្នាំឲ្យឈាមកក (clotting factor concentrates)។
- អ្នកដែលធ្វើការជាមួយនឹងសត្វផ្ទុកមេរោគ HAV ឬដែលធ្វើការជាមួយនឹងមេរោគ HAV ក្នុងមន្ទីរពិសោធន៍ស្រាវជ្រាវ។
- សមាជិកក្នុងគ្រួសារ ដែលគ្រោងសុំកូន ឬថែទាំកូនដែលទើបសុំថ្មីពីប្រទេសដែលកើតជំងឺរលាកថ្លើមប្រភេទ A ជាទូទៅ។

*អ្នកផ្សេងទៀតអាចទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A ក្នុងស្ថានការណ៍មួយចំនួន (សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នកដើម្បីទទួលបានសេចក្តីលំអិតបន្ថែមទៀត) ៖*

- កុមារ ឬយុវជនដែលមិនបានចាក់ថ្នាំវ៉ាក់សាំង ក្នុងសហគមន៍ដែលកើតមានករណីជំងឺរលាកថ្លើមប្រភេទ A។
- អ្នកដែលមិនបានដាក់ថ្នាំវ៉ាក់សាំង ដែលបានប៉ះពាល់នឹងមេរោគជំងឺរលាកថ្លើមប្រភេទ A។
- អ្នកមានអាយុ 1 ឆ្នាំ ឬលើសនេះ ដែលចង់បានការការពារប្រឆាំងនឹងជំងឺរលាកថ្លើមប្រភេទ A។

ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A ពុំត្រូវបានអនុញ្ញាតសម្រាប់កុមារអាយុតិចជាង 1 ឆ្នាំឡើយ។

### តើនៅពេលណា?

**ចំពោះកុមារ** ថ្នាំវ៉ាក់សាំងដូសទី 1 គួរចាត់នៅអាយុ 12 ដល់ 23 ខែ។ កុមារ ដែលមិនបានចាក់ថ្នាំវ៉ាក់សាំងនៅមុនអាយុ 2 ឆ្នាំ អាចចាក់ថ្នាំវ៉ាក់សាំងនេះបាន នៅពេលទៅជួបវេជ្ជបណ្ឌិតលើកក្រោយ។

**ចំពោះអ្នកដទៃទៀតដែលស្ថិតក្នុងហានិភ័យ** ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A អាចចាប់ផ្តើមចាក់ នៅពេលចង់ទទួលបានការការពារ ឬនៅពេលមានហានិភ័យអាចឆ្លងជំងឺនេះ។

**ចំពោះអ្នកធ្វើដំណើរវិញ** ជាការល្អប្រសើរបំផុតត្រូវចាប់ផ្តើមចាក់ថ្នាំវ៉ាក់សាំងយ៉ាងហោចណាស់ 1 ខែមុនពេលធ្វើដំណើរ។ (នៅតែអាចមានការការពារមួយចំនួន ប្រសិនបើផ្តល់ថ្នាំវ៉ាក់សាំងនៅ ឬកែកនឹងថ្ងៃធ្វើដំណើរ។)

> មនុស្សមួយចំនួន ដែលមិនអាចទទួលថ្នាំវ៉ាក់សាំងមុនពេលធ្វើដំណើរ ឬដែលថ្នាំវ៉ាក់សាំងមិនអាចមានប្រសិទ្ធិភាពនោះ អាចចាក់ថ្នាំមួយទៀតដែលគេហៅថា immune globulin (IG)។ ថ្នាំ IG ផ្តល់ការការពារភ្លាមៗជាបណ្តោះអាសន្ន។

គេត្រូវការថ្នាំវ៉ាក់សាំងចំនួនពីរដូស ដើម្បីទទួលបានការការពាររយៈពេលវែង។ ចំនួនដូសទាំងនេះគួរចាក់ក្នុងរយៈពេលយ៉ាងហោចណាស់ 6 ខែដាច់ពីគ្នា។

ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A អាចចាក់នៅពេលដំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀត។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 3 មនុស្សមួយចំនួនមិនគួរចាក់ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A ទេ ឬគួររង់ចាំ។

- អ្នកដែលធ្លាប់មានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ (ដែលគំរាមដល់អាយុជីវិត) នឹងថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A មួយដូសមុន មិនគួរទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A មួយដូសផ្សេងទៀតទេ។
- អ្នកដែលធ្លាប់មានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ (ដែលគំរាមដល់អាយុជីវិត) នឹងធាតុផ្សំក្នុងថ្នាំវ៉ាក់សាំងមិនគួរទទួលថ្នាំវ៉ាក់សាំងទេ។
- **សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើលោកមានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ** ដែលរាប់ទាំងប្រតិកម្មអាឡាក់ស៊ីទៅនឹងជាតិជ័រ (latex)។ ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A ទាំងអស់ មានធាតុផ្សំអាលុយមីញ៉ូម ហើយថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A មួយចំនួន មានធាតុផ្សំ 2-phenoxyethanol។
- អ្នកដែលមានជំងឺធ្ងន់ល្មម ឬធ្ងន់ធ្ងរ នៅពេលកំណត់ចាក់ថ្នាំវ៉ាក់សាំង គួររង់ចាំរហូតទាល់តែជាសះស្បើយសិន។ សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នក។ ជាធម្មតា អ្នកមានជំងឺស្រាលអាចចាក់ថ្នាំវ៉ាក់សាំងបាន។
- សូមប្រាប់វេជ្ជបណ្ឌិតរបស់អ្នក ប្រសិនបើអ្នកមានផ្ទៃពោះ។ ដោយសារតែថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A គឺអសកម្ម (មេរោគត្រូវបានសម្លាប់) ហានិភ័យចំពោះស្ត្រីមានផ្ទៃ ឬទារកមិនទាន់កើត ត្រូវបានគេជឿជាក់ថា មានកម្រិតទាបណាស់។ ប៉ុន្តែវេជ្ជបណ្ឌិតរបស់លោកអ្នកអាចធ្វើការថ្លឹងថ្លែងរវាងហានិភ័យដោយសារថ្នាំវ៉ាក់សាំងតាមទ្រឹស្តី ជាមួយនឹងសេចក្តីត្រូវការដែលចង់បានការការពារប្រឆាំងនឹងជំងឺរលាកថ្លើមប្រភេទ A។

## 4 តើមានហានិភ័យអ្វីខ្លះដោយសារថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A?

ថ្នាំវ៉ាក់សាំង គឺដូចឱសថផងដែរ គឺអាចបង្កបញ្ហាធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ ហានិភ័យដែលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A បង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតនោះ គឺមានកម្រិតតិចបំផុត។

ការទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A គឺមានសុវត្ថិភាពច្រើនជាងការឆ្លងជំងឺនេះ។

### បញ្ហាស្រាល

- ដំបៅនៅត្រង់ចាក់ថ្នាំវ៉ាក់សាំង *(មនុស្សពេញវ័យប្រហែលម្នាក់ក្នុងចំណោម 2 នាក់ ហើយកុមារប្រហែលម្នាក់ក្នុងចំណោម 6 នាក់)*
- ឈឺក្បាល *(មនុស្សពេញវ័យប្រហែលម្នាក់ក្នុងចំណោម 6 នាក់ និងកុមារប្រហែលម្នាក់ក្នុងចំណោម 25 នាក់)*
- ការបាត់បង់ចំណង់អាហារ*(កុមារប្រហែលម្នាក់ក្នុងចំណោម 12 នាក់)*
- ណឿយហត់*(មនុស្សពេញវ័យម្នាក់ក្នុងចំណោម 14 នាក់)*

ប្រសិនបើបញ្ហាទាំងនេះកើតឡើង ជាធម្មតាបញ្ហាទាំងនេះកើតឡើង 1 ឬ 2 ថ្ងៃ។

### បញ្ហាធ្ងន់ធ្ងរ

- ប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ រយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោងប៉ុណ្ណោះ បន្ទាប់ពីការចាក់ថ្នាំវ៉ាក់សាំង *(កម្រណាស់)*។

DCH-0452CA
AUTH: P. H. S. , Act 42, Sect. 2126.

Translation provided by the Immunization Action Coalition

## 5 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?**

- សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬការប្តូរឥរិយាបថ។

  សញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ អាចរួមបញ្ចូលកន្ទួល ហើមមុខនិងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ។ បញ្ហាទាំងនេះនឹងចាប់ផ្តើមកើតឡើងរយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោងប៉ុណ្ណោះ បន្ទាប់ពីការចាក់ថ្នាំវ៉ាក់សាំង។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើលោកអ្នកគិតថា វាគឺជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬយកអ្នកជំងឺទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ បើមិនអញ្ចឹងទេ សូមទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក។
- បន្ទាប់មក ប្រតិកម្មគួររាយការណ៍ទៅប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (Vaccine Adverse Event Reporting System (VAERS))។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈវេបសាយ VAERS នៅ **www.vaers.hhs.gov** ឬតាមរយៈហៅទូរស័ព្ទមក **1-800-822-7967**។

*VAERS គឺសម្រាប់តែការរាយការណ៍ប្រតិកម្មផ្សេងៗប៉ុណ្ណោះ។ ប្រព័ន្ធនេះពុំផ្តល់ដំបូន្មានវេជ្ជសាស្ត្រទេ។*

## 6 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (National Vaccine Injury Compensation Program)

កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (National Vaccine Injury Compensation Program (VICP)) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយ អាចធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក**1-800-338-2382** ឬចូលទៅវេបសាយ VICP នៅ **www.hrsa.gov/vaccinecompensation**។

## 7 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នក។ 1-888-767-4687
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- ទាក់ទងមជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺឆ្លង (CDC):
  - ទូរស័ព្ទមកលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅវេបសាយ CDC នៅ **www.cdc.gov/vaccines**

Vaccine Information Statement (Interim)
# Hepatitis A Vaccine

10/25/2011 Khmer

42 U.S.C. § 300aa-26

Office Use Only

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។